សលាកប័ត្រព័ត៌មាន ៖ ច្បាប់ស្តីពីសេរីភាពក្នុងការទទួលព័ត៌មាន
ពេលវេលា ៖ គណបក្សប្រឆាំងបានបញ្ជូនច្បាប់ទៅកាន់រដ្ឋសភាដើម្បីធ្វើការពិចារណា
ការធ្វើចំណាត់ថ្នាក់ដោយ ម.ស.ម.ក ៖ លឿង



រូបភាពរួម ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ចាត់ចំណាត់ថ្នាក់ពណ៌លឿងសម្រាប់សេចក្តីស្នើច្បាប់ស្តីពីសេរីភាពក្នុងការទទួលព័ត៌មាន (សេចក្តីស្នើច្បាប់) ដោយសារតែច្បាប់នេះមានបញ្ញត្តិវិជ្ជមានមួយចំនួន ដែលជួយជំរុញដល់សេរីភាពក្នុងការទទួលបានព័ត៌មាន ហើយរួមជាមួយគ្នានោះដែរ អ្វីដែលសំខាន់គឺច្បាប់នេះមានចែងស្តីពីស្ថាប័នឯករាជ្យដែលអនុញ្ញាតឲ្យប្រជាពលរដ្ឋអាចធ្វើការប្តឹងផ្តល់ក្នុងលក្ខខណ្ឌដែលសិទ្ធិសេរីភាពទទួលបានព័ត៌មានត្រូវបានរំលោភបំពាន ។ ក៏ប៉ុន្តែ សេចក្តីស្នើច្បាប់នេះនៅមានចំណុចមួយចំនួនដែលនៅតម្រូវឲ្យមានការកែលម្អ ដូចជា ខ្លឹមសារនៃច្បាប់នេះមួយចំនួនមានលក្ខណៈមិនច្បាស់លាស់ដែលអាចបំពាន ឬបកស្រាយក្នុងផ្លូវដែលអាចបណ្តាលឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពទទួលបានព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា (កម្ពុជា) ។

សេចក្តីផ្តើម

សលាកប័ត្រព័ត៌មានបង្ហាញរូបភាពរួមនៃ សេចក្តីស្នើច្បាប់ស្តីពីសេរីភាពទទួលបានព័ត៌មាន ដែលមានគោលបំណងលើកដម្កើង សេរីភាពទទួលបានព័ត៌មាននៅកម្ពុជា និងស្ថាប័នឯករាជ្យដែលមាននៅក្នុងគោលបំណងរបស់សេចក្តីស្នើច្បាប់ដែលអាចជួយរកដំណោះស្រាយជូនប្រជាពលរដ្ឋសាមញ្ញ ក្នុងករណីដែលសិទ្ធិសេរីភាពទទួលបានព័ត៌មានរបស់ពួកគាត់ត្រូវបានរំលោភបំពាន ។ សលាកប័ត្រព័ត៌មាននេះសរសេរដោយ ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្ស-សម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិនយោបាយ សិទ្ធិពលរដ្ឋនៅកម្ពុជា។

សាវតារ

សិទ្ធិក្នុងការទទួលបានព័ត៌មាន ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ថាជាសិទ្ធិមនុស្សមូលដ្ឋាន ។ សិទ្ធិនេះក៏ជាគោលការណ៍មួយនៃលទ្ធិប្រជាធិបតេយ្យផងដែរ ។ រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) បានបង្ហាញឆន្ទៈរបស់ខ្លួនចំពោះសិទ្ធិសេរីភាពខាងព័ត៌មានតាមរយៈការរៀបចំសេចក្តីព្រាងគោលនយោបាយសេរីភាពខាងព័ត៌មាន ។ ទោះជាយ៉ាងនេះក្តី ការចង់បានព័ត៌មាន និងសិទ្ធិទទួលបានព័ត៌មានសាធារណៈ នៅតែស្ថិតនៅឆ្ងាយពីអ្វីដែលបានចាក់ឫសនៅក្នុងសង្គមកម្ពុជា ។ នៅខែធ្នូ ឆ្នាំ២០១០ តំណាងគណបក្ស សម រង្ស៊ី បានបញ្ជូនសេចក្តីព្រាង ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ជូនទៅកាន់រដ្ឋសភា ប៉ុន្តែសេចក្តីស្នើច្បាប់នេះ ដែលត្រូវបានត្រួតពិនិត្យ និងវិភាគដោយអង្គការមាត្រា១៩ ដែលមានការិយាល័យនៅទីក្រុងឡុងដ៍ ត្រូវបានរាយការណ៍ថាធ្លាប់ត្រូវបានរដ្ឋសភាបដិសេធ ដោយគ្មានការត្រួតពិនិត្យ ឬជជែកដេញដោល ។ ក្នុងខែមិនា ឆ្នាំ២០១២ គណបក្ស សម រង្ស៊ី បានបញ្ជូនសេចក្តីព្រាងច្បាប់មួយច្បាប់ទៀតទៅកាន់រដ្ឋសភា (សេចក្តីព្រាងនោះមានបញ្ចូលនូវមតិយោបល់របស់អង្គ-ការមាត្រា១៩) សូមអានការវិភាគដូចខាងក្រោម ។

ការវិភាគលើសេចក្តីស្នើច្បាប់

សេចក្តីស្នើច្បាប់នេះ មានចំណុចវិជ្ជមានមួយចំនួន ពាក់ព័ន្ធនឹងការអនុវត្តន៍ច្បាប់ទាំងមូល ដូចជា មាត្រា៦ បានចែងពីករណីកិច្ចក្នុងការបោះពុម្ពផ្សាយ ដែលតម្រូវឲ្យស្ថាប័នសាធារណៈ ទាំងអស់ត្រូវបោះពុម្ព និងផ្សព្វផ្សាយយ៉ាងតិចបំផុតជារៀងរាល់ឆ្នាំ នូវរាល់ឯកសារ និងព័ត៌មានសំខាន់ៗ ស្តីពីស្ថាប័នរបស់ខ្លួនក្នុងទម្រង់ដែលអាចទទួលយកបាន ។ មាត្រា៦ ក៏បានរៀបរាប់ពីប្រភេទឯកសារតែតម្រូវឲ្យមានការបោះពុម្ពផ្សាយផងដែរ ។ បន្ថែមពីលើនោះ មាត្រា៩ រាជរដ្ឋាភិបាលកម្ពុជាត្រូវផ្សព្វផ្សាយទៅដល់សាធារណជនឲ្យបានដឹងឮស្លាមៗ អំពីសេចក្តីព្រាងច្បាប់សាធារណៈ បទបញ្ជា គោលនយោបាយ និងឯកសារដទៃទៀតដែលជាប្រយោជន៍ដល់សាធារណៈ:ពេលដែលឯកសារទាំងនោះបានប្រគល់ទៅដល់គណៈរដ្ឋមន្ត្រី ។ ការកំណត់ជាកាតព្វកិច្ចដល់រដ្ឋាភិបាលក្នុងការផ្សព្វផ្សាយ ច្បាប់ ឬគោលនយោបាយ មាត្រា៩នៃច្បាប់នេះបានផ្តល់ឱកាសឲ្យសាធារណជនបានដឹងឮពីសកម្មភាពរបស់រដ្ឋាភិបាល ហើយជាពិសេសគឺសេចក្តីសម្រេចដែលនឹងអាចប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃរបស់ពួកគាត់ ។

ចំណុចវិជ្ជមានមួយទៀតនៃច្បាប់នេះ គឺសេចក្តីណែនាំពីការប្រើប្រាស់សេចក្តីស្នើច្បាប់ ដែលមានបំណងផ្តល់ការការពារមិនឲ្យមានការអនុវត្តន៍ច្បាប់ផ្ទុយពីគោលដៅ ឬក៏អនុវត្តន៍ច្បាប់ដោយមិនត្រឹមត្រូវ ។ យោងតាម មាត្រា១២ ស្នងការព័ត៌មានគឺជាអ្នកបង្កើតនូវសេចក្តីណែនាំពីការប្រើប្រាស់ច្បាប់នេះ ។ ស្នងការព័ត៌មានគឺជាស្ថាប័នឯករាជ្យ ដើម្បីត្រួតពិនិត្យ និងរាយការណ៍អំពីការប្រព្រឹត្តទៅរបស់ស្ថាប័នសាធារណៈ: ធ្វើការសម្រេចលើបណ្តឹងរបស់ប្រជាពលរដ្ឋអំពីការបដិសេធមិនព្រមផ្តល់

ព័ត៌មានរបស់ស្ថាប័នសាធារណៈ ផ្តល់អនុសាសន៍សម្រាប់ធ្វើការកំណែទម្រង់ ផ្តល់សកម្មភាពបណ្តុះបណ្តាលដល់មន្ត្រីសាធារណៈស្តីពីសិទ្ធិសេរីភាពទទួលព័ត៌មាន និងផ្សព្វផ្សាយជាសាធារណៈអំពីតម្រូវការនៃច្បាប់នេះ និងសិទ្ធិបុគ្គលក្រោមច្បាប់នេះ ។

ជំពូកទី៨ នៃច្បាប់នេះមានចែងពីសាលាជំរះក្តីផ្នែកព័ត៌មាន ដែលមានតួនាទីសម្រេចលើពាក្យសុំពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់ស្នងការ ។ មួយវិញទៀត ក្នុងករណីដែលភាគីមិនពេញចិត្តចំពោះសេចក្តីសម្រេចរបស់សាលាជំរះក្តី ភាគីអាចមានសិទ្ធិដាក់បណ្តឹងឧទ្ធរណ៍ ទៅតុលាការកំពូលក្នុងរយៈពេល ២៨ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេច ។ ជំពូកនេះបានផ្តល់ប្រយោជន៍ជាច្រើនដល់សាធារណជន ដូចជា នីតិវិធីស្របច្បាប់ដែលពួកគាត់អាចស្វែងរកបាន ក្នុងករណីដែលពួកគាត់មិនពេញចិត្តចំពោះសេចក្តីសម្រេច របស់ស្នងការព័ត៌មាន និងសាលាជំរះក្តីព័ត៌មាន ។

មាត្រា៦៨ ចែងថា "*ដោយពុំគិតពីការបំពានលើកាតព្វកិច្ចការងារ ឬ ផ្លូវច្បាប់ គ្មានបុគ្គលណាអាចត្រូវទទួលទណ្ឌកម្មទាក់ទិនទៅនឹងការងារ ឬ រដ្ឋបាល ឬ ច្បាប់ សម្រាប់ការលាតត្រដាងនូវព័ត៌មាន អំពីការប្រព្រឹត្តកំហុស ឬ ការគំរាមគំហែងធ្ងន់ធ្ងរទៅលើសុខភាពសុវត្ថិភាព ឬ បរិស្ថាន ក្នុងខណៈដែលពួកគេលាតត្រដាង ដោយស្មោះត្រង់ និង ដោយជំនឿយ៉ាងសមហេតុផលថាព័ត៌មានទាំងនេះ គឺពិតយ៉ាងច្បាស់ និង បង្ហាញឲ្យឃើញអំពីកស្តុតាង នៃការប្រព្រឹត្តកំហុស ឬ គំរាមកំហែងធ្ងន់ធ្ងរចំពោះសុខភាព សុវត្ថិភាព និងបរិស្ថាន*" ។ បញ្ញត្តនេះមានបំណងជំរុញឲ្យមានការចូលរួមពីសាក្សី ឬអ្នកផ្តល់ព័ត៌មាន ដោយសារតែមានការការពារស្របច្បាប់ និងធានាថាពួកគាត់អាចផ្តល់ព័ត៌មានដែលសមស្របសម្រាប់សាធារណជន ។

ក៏ប៉ុន្តែ មានចំណុចមួយចំនួននៅក្នុងសេចក្តីស្នើច្បាប់ដែលគួរតែមានការកែលម្អ ។ ចំណុចទីមួយ ភាសាដែលច្បាប់នេះប្រើប្រាស់មានលក្ខណៈស្មុគស្មាញ ។ ភាសាក្នុងច្បាប់គួរតែគ្មានលក្ខណៈស្មុគស្មាញ ព្រោះថាអាចរារាំងដល់អាជ្ញាធរមូលដ្ឋានក្នុងការអនុវត្តច្បាប់ ឬក៏ធ្វើឲ្យប្រជាពលរដ្ឋអានមិនយល់ និងមិនអាចទាញយកប្រយោជន៍ពីសេចក្តីស្នើច្បាប់នេះបាន ។ មិនតែប៉ុណ្ណោះ ពាក្យពេចន៍មួយចំនួនក្នុងច្បាប់នេះដែលមិនច្បាស់ ។ ពិតជាមានសារៈសំខាន់ណាស់ ដែលពាក្យវាក្យសព្ទក្នុងច្បាប់ត្រូវតែផ្តល់និយមន័យឲ្យសមស្រប ។ ឧទាហរណ៍ សេចក្តីស្នើច្បាប់នេះមិនបានចែកដាច់រវាងស្ថាប័នសាធារណៈ និងស្ថាប័នឯកជន ចំណែកនិយមន័យក៏មានលក្ខណៈទូលាយ ដែលអាចមានចន្លោះប្រហោងក្នុងការអនុវត្តន៍ខុស និងយល់ខុស ។ បញ្ញត្តមួយចំនួនគឺហាក់ដូចជាមិនចាំបាច់ ឧទាហរណ៍ មាត្រា៤ ចែងថាសេចក្តីស្នើច្បាប់អនុវត្តន៍ចំពោះតុលាការ ប៉ុន្តែតុលាការជាអំណាចមួយក្នុងអំណាចទាំងបីរបស់រដ្ឋ ដូច្នេះ សេចក្តីស្នើច្បាប់នេះគួរមានវិសាលភាពគ្របដណ្តប់រាល់ស្ថាប័នរដ្ឋាភិបាលទាំងអស់ ដោយមិនចាំបាច់ត្រូវមានបញ្ញត្តចែងដោយឡែកនោះទេ ។ ជាចុងក្រោយ តាមរយៈការកត់សម្គាល់របស់ អង្គការមាត្រា១៩ សេចក្តីស្នើច្បាប់មិនបានបញ្ជាក់ច្បាស់ថាត្រូវមានការសន្មត់ជាមុនថារាល់ព័ត៌មានរបស់ស្ថាប័នសាធារណៈទាំងអស់ត្រូវតែផ្សព្វផ្សាយ លើកលែងតែក្នុងកាលៈទេសៈចាំបាច់បំផុត ។

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ច្បាប់នេះមានបញ្ញត្តិវិជ្ជមានមួយចំនួន ដែលអាចជួយសម្របសម្រួលដល់សិទ្ធិ និងលទ្ធភាពទទួលព័ត៌មានរបស់ប្រជាពលរដ្ឋទូទៅ និងធានាថាប្រជាពលរដ្ឋនឹងអាចទទួលបានព័ត៌មានដែលពួកគាត់ត្រូវការឲ្យបានស្របទាន់ពេលវេលា ដែលធ្វើឲ្យពួកគាត់អាចធ្វើការសម្រេចចិត្តលើបញ្ហាសំខាន់ៗ ដែលមានផលប៉ះពាល់ដល់ពួកគាត់ និងជីវភាពប្រចាំថ្ងៃរបស់ពួកគាត់ ។ ក៏ប៉ុន្តែ ដើម្បីកាត់បន្ថយនូវចំណុចខ្វះខាតក្នុងច្បាប់នេះ ម.ស.ម.ក សូមផ្តល់អនុសាសន៍ដូចខាងក្រោម ៖

- ភាសាដែលប្រើគួរតែសាមញ្ញ និងងាយយល់ ដើម្បីឲ្យប្រជាពលរដ្ឋអាចអាន និងយល់បាន
- វាក្យសព្ទដែលមិនច្បាស់លាស់គួរតែត្រូវបានផ្តល់និយមន័យឲ្យសមស្រប ដូចជា និយមន័យនៃពាក្យ ស្ថាប័នសាធារណៈ និងស្ថាប័នឯកជន គួរតែត្រូវបានចែកឲ្យដាច់ពីគ្នា និងផ្តល់និយមន័យឲ្យច្បាស់លាស់ជាងនេះ
- សេចក្តីស្នើច្បាប់នេះគួរតែមានវិសាលភាពគ្របដណ្តប់លើគ្រប់ផ្នែកទាំងអស់នៃរដ្ឋាភិបាល ដូចជា អំណាចនីតិប្រតិបត្តិ អំណាចនីតិបញ្ញត្ត និងអំណាចតុលាការផងដែរ មិនតែប៉ុណ្ណោះគឺរាល់ស្ថាប័នដែលបំពេញមុខងារសាធារណៈ ឬទទួលមូលនិធិសាធារណៈ និង
- ត្រូវមានការសន្មត់ជាមុនថារាល់ព័ត៌មានរបស់ស្ថាប័នសាធារណៈទាំងអស់គួរតែត្រូវបានផ្សព្វផ្សាយ លើកលែងតែក្នុងកាលៈទេសៈចាំបាច់បំផុត ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង កញ្ញា សន វ៉ាមណា (+៨៥៥ (0) ១៧ ៦៥ ៥៥ ៩១) ឬអ៊ីម៉ែល៖ ramanasorn@cchrcambodia.org ឬ លោក រ៉ូប៊ឺត ហ្វីនជ៍ (+៨៥៥ (0) ៧៨ ៨0 ៩៩ ៦0 ឬអ៊ីម៉ែល៖ robert.finch@cchrcambodia.org ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights